# ការអនុវត្តបន្តរបស់អ្នក

# ដើម្បីសិទ្ធិរបស់ខ្ញុំ

## នៅប្រទេសកម្ពុជា

# YOUR NEXT ACTIONS FOR MY RIGHTS IN CAMBODIA



# មាតិកា Contents


ច្បាប់ គោលនយោបាយ ការចាត់ចែងធនធានថវិកាសម្រាប់អនុវត្ត — 01
Laws, Policies, and Resource Allocation

គោលការណ៍ទាំងបួននៃអនុសញ្ញាស្តីពីសិទ្ធិកុមារ — 05
Four General Principles of The CRC

សិទ្ធិ និងសេរីភាពជាពលរដ្ឋរបស់កុមារ — 09
Civil Rights and Freedoms

អំពើហិង្សាលើកុមារ — 13
Violence Against Children

សិទ្ធិទទួលបានការរស់នៅជាមួយគ្រួសារ និងការថែទាំជំនួស — 17
Family Environment and Alternative Care

សិទ្ធិកុមារមានពិការភាព — 21
Children With Disabilities

សុខភាព និងសុខុមាលភាពសម្រាប់កុមារ — 23
Health and Welfare

អប់រំ សកម្មភាពកម្សាន្ត និងវប្បធម៌សម្រាប់កុមារ — 27
Education, Leisure, and Cultural Activities

កិច្ចការពារពិសេសសម្រាប់កុមារ — 31
Special Protection

# ពេលវេលានៃសកម្មភាពសំខាន់ៗនៅប្រទេសកម្ពុជា

## Key Dates

**1992**

ប្រទេសកម្ពុជាបានផ្តល់
សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារ

Cambodia joined the UN
Convention on the Rights of the Child (CRC)

**1997, 2009, 2018**

រាជរដ្ឋាភិបាលបានផ្ញើរបាយការណ៍
ចំនួន៣លើកពីការអនុវត្តសិទ្ធិកុមារទៅ
គណកម្មាធិការ អ.ស.ប ស្តីពីសិទ្ធិកុមារ។

Cambodian Government submitted
three periodic reports on the child rights implementation
to the UN Committee on the Rights of the Child (CRC Committee)

**2004, 2010, 2019**

កុមាររៀបចំ និងបានផ្ញើរបាយការណ៍របស់
កុមារ និងយុវជនចំនួន៣លើកពីការ
អនុវត្តសិទ្ធិកុមារទៅគណកម្មាធិការ
សិទ្ធិកុមារ។

Cambodian children developed and
submitted their own reports three times to the CRC
Committee on the child rights situation in Cambodia.

## តើសៀវភៅនេះនិយាយអំពីអ្វី

ប្រទេសកម្ពុជាបានយល់ព្រមការពារ គោរព និងបំពេញសិទ្ធិកុមារដែលមាននៅក្នុងអនុសញ្ញាស្ដីពីសិទ្ធិកុមារដែលជាច្បាប់អន្តរជាតិ។ អង្គការសហប្រជាជាតិមានគណៈកម្មាធិការសិទ្ធិកុមារមួយដែលជាក្រុមនៃអ្នកជំនាញការឯករាជ្យនៃសិទ្ធិកុមារដើម្បីជួយប្រទេសជាសមាជិកក្នុងការអនុវត្តសិទ្ធិកុមារ។ កន្លងមក គណៈកម្មាធិការសិទ្ធិកុមារបានពិនិត្យនូវស្ថានភាពសិទ្ធិកុមារនៅប្រទេសកម្ពុជា និងផ្ដល់ជាអនុសាសន៍ ឬសំណូមពរសម្រាប់ប្រទេសកម្ពុជាតាមរយៈឯកសារមួយដែលមានឈ្មោះថាសេចក្ដីអង្កេតចុងក្រោយស្ដីពីសិទ្ធិកុមារ។ កុមារកម្ពុជាក៏បានចូលរួមយ៉ាងសកម្មក្នុងការផ្ដល់ព័ត៌មានទៅគណៈកម្មាធិការសិទ្ធិកុមារ និងធ្វើការជាមួយរដ្ឋាភិបាលក្នុងការអនុវត្តនូវសំណូមពរទាំងនោះ។

សៀវភៅនេះបានសរសេរសង្ខេបនូវខ្លឹមសារសំណូមពរពីគណៈកម្មាធិការក្នុងឆ្នាំ២០២២សម្រាប់ប្រទេសកម្ពុជា។ យើងខ្ញុំសូមលើកទឹកចិត្តឱ្យប្អូនៗទាំងអស់គ្នាជាកុមារចូលរួមជាមួយយើងដើម្បីជួយប្រទេសកម្ពុជាអនុវត្តសិទ្ធិកុមារបន្តទៀត។

## What is this booklet about

Cambodia has agreed to protect, respect, and fulfill the rights of all children as listed under the UN Convention on the Rights of the Child, which is an international agreement. The UN Committee on the Rights of the Child is a group of experts that help countries to carry out their duties for children. From time to time, the Committee reviews the situation of children's rights in Cambodia and provides recommendations to the government through what are called Concluding Observations. Cambodian children have played an important role in providing information to the Committee and in working with the government to implement the recommendations.

In this booklet, we give you a very brief summary of the recommendations provided by the Committee to Cambodia in June 2022. We invite you to join us in helping Cambodia to take their next actions for children's rights!

# អនុសាសន៍ ឬសំណូមពររបស់ អង្គការសហប្រជាជាតិឆ្នាំ២០២២ សម្រាប់ ប្រទេសកម្ពុជាអនុវត្តបន្តនូវសិទ្ធិកុមារ

១. បង្កើតច្បាប់ ផែនការ សកម្មភាពដូចជាច្បាប់ការពារកុមារ ដើម្បីការពារ និងគាំទ្រដល់កុមារគ្រប់រូបនៅក្នុងប្រទេសព្រមទាំងផ្តល់នូវធនធាន ឬថវិកាគ្រប់គ្រាន់សម្រាប់អនុវត្តឱ្យបានទៅដល់កុមារ។

២. ផ្សព្វផ្សាយដល់ឪពុកម្តាយ គ្រូបង្រៀន មន្ត្រីផ្នែកសុខភាព អ្នកផ្តល់សេវាសង្គម នគរបាល មេធាវី តុលាការ និងអ្នកមានតួនាទីដទៃទៀត ឱ្យបានយល់ដឹងពីសិទ្ធិរបស់កុមារ និងអ្វីដែលពួកគេត្រូវធ្វើដើម្បីគោរពតាមសិទ្ធិកុមារ។

៣. ធានាឱ្យកុមារគ្រប់រូបដែលមានអត្តញ្ញាណ និងប្រវត្តិផ្សេងៗគ្នាបានទទួលសេវាសង្គម និងត្រួតពិនិត្យលើសេវាទាំងនោះទៅដល់កុមារឬទេ ព្រមទាំងផ្សព្វផ្សាយ និងអប់រំដល់មនុស្សគ្រប់រូបពីការមិនរើសអើងចំពោះកុមារ និងបញ្ជាក់ថាកុមារគ្រប់រូបមានសិទ្ធិស្មើៗគ្នា។

៤. ធានាថាសកម្មភាពផ្សព្វផ្សាយពីសុវត្ថិភាពនៅលើដងផ្លូវ និងទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍បន្ថែមទៀត។

៥. ធានាថាសម្លេងរបស់កុមារត្រូវបានបញ្ចូលទៅក្នុងសេចក្តីសម្រេចចិត្តនានាដែលពាក់ព័ន្ធនឹងជីវិតកុមារដូចជានៅក្នុងដំណើរការសុំកូនយកទៅចិញ្ចឹមក្នុងដំណើរការ ឬក្នុងការរៀបចំផែនការដែលពាក់ព័ន្ធ នឹងកុមារនៅក្នុងគ្រួសារសហគមន៍ សាលារៀន និងនៅស្ថាប័នរដ្ឋនានា។

៦. ធានាថាកុមារគ្រប់រូបបានចុះបញ្ជី ឬទទួលបានសំបុត្រកំណើត និងឯកសារសម្គាល់អត្តសញ្ញាណដទៃទៀតដោយកែលំអប្រព័ន្ធចុះសំបុត្រកំណើត និងហាមឃាត់ការយកថ្លៃសេវាពីការចុះបញ្ជីនេះ។

៧. ធានាថាកុមារគ្រប់រូបអាចបញ្ចេញនូវទស្សនៈរបស់ពួកគេដោយសេរីនៅផ្ទះ សហគមន៍ សាលារៀន កន្លែងការងាររបស់រដ្ឋ និងនៅប្រព័ន្ធទំនាក់ទំនងសង្គម។

៨. ជួយគាំទ្រកុមារក្នុងការបង្កើតអង្គការ ក្រុមឬក្លឹប គំនិតផ្តួចផ្តើមថ្មីរបស់ពួកគេ និងការចូលរួមនូវការជួបជុំជាសាធារណៈនានា។

៩. បង្កើតច្បាប់ការពារសិទ្ធិកុមារ សិទ្ធិឯកជនភាពរបស់កុមារ និងសុវត្ថិភាពរបស់ពួកគេនៅក្នុងប្រព័ន្ធអនឡាញ និងអ៊ិនធើណេត ព្រមទាំងជួយកុមារ ឪពុកម្តាយ គ្រូបង្រៀន និងអ្នកផ្តល់សេវាសង្គមប្រើប្រាស់ប្រព័ន្ធនោះដោយសុវត្ថិភាព និងគោរពគ្នាទៅវិញទៅមក។

១០. មិនឱ្យអ្នកណាម្នាក់ដាក់ទណ្ឌកម្មបែបហិង្សាលើកុមារ ជួយគាំទ្រការអនុវត្តវិន័យ និងការចិញ្ចឹមកូនបែបវិជ្ជមាន និងមិនមានហិង្សានៅផ្ទះ សហគមន៍ និងសាលារៀន។ គាំទ្រនូវសកម្មភាពការចិញ្ចឹមកូនដោយវិជ្ជមាន ឬមិនប្រើហិង្សា។ ផ្តល់សេវាប្រព័ន្ធទូរស័ព្ទជំនួយកុមារដោយឥតគិតថ្លៃ និងងាយទាក់ទងបានដោយមានការបង្រៀនកុមារពីវិធីទាក់ទងទៅសេវានោះផងដែរ។

១១. ធានាថាកុមារដែលទុកដាក់នៅក្នុងមន្ទីរឃុំឃាំងមិនទទួលរងនូវអំពើហិង្សា ហើយពួកគេអាចចែករំលែកពីបញ្ហារបស់ពួកគេដោយសម្ងាត់ទៅអ្នកខាងក្រៅពីអំពើនានាដែលប្រព្រឹត្តចំពោះពួកគេ។

១២. ផ្សព្វផ្សាយដល់មនុស្សគ្រប់រូបពីផលប៉ះពាល់ និងភាពរងគ្រោះចេញពីការប្រព្រឹត្តបែបប្រពៃណីមិនសមរម្យ និងការរៀបការនៅវ័យកុមារ ព្រមទាំងបញ្ឈប់រាល់អំពើទាំងនោះ។

១៣. ឱ្យកុមារស្នាក់នៅក្នុងការថែទាំជំនួសឬក្រៅពីគ្រួសារនៅក្នុងសហគមន៍នៅពេលគ្រួសាររបស់កុមារមិនអាចថែទាំកុមារបាន ដូចជាស្នាក់នៅជាមួយសាច់ញាតិជិតដិតឬជាមួយគ្រួសារមួយទៀតនៅក្នុងសហគមន៍ដែលអាចជួយថែទាំកុមារបានល្អ។

១៤. ធានាថាសកម្មភាពសូមកូនយកទៅចិញ្ចឹមធ្វើតាមច្បាប់ និងទប់ស្កាត់កុមារពីអំពើជួញដូរតាមរូបភាពសូមកូនយកទៅចិញ្ចឹម។ ប្រមូលព័ត៌មានពីគ្រួសារដែលមានលក្ខណៈគ្រប់គ្រាន់អាចសូមកូនយកមកចិញ្ចឹមបាននៅក្នុងប្រទេស។

១៥. ផ្សព្វផ្សាយដល់មនុស្សគ្រប់រូបពីសិទ្ធិរបស់កុមារដែលមានពិការភាព និងធានាថាពួកគេមិនទទួលរងអំពើហិង្សា ឬសកម្មភាពមិនយុត្តិធម៌ឬមិនស្មើភាព។

១៦. បង្កើតសកម្មភាពគាំទ្រសុខភាពផ្លូវចិត្តដល់កុមារ ផ្តល់ការអប់រំដល់កុមារពីសុខភាពបន្តពូជ ឬសុខភាពផ្លូវភេទ ពីបរិស្ថាន និងពីបម្រែបម្រួលអាកាសធាតុ ព្រមទាំងពិចារណាពីតម្រូវការ បញ្ហា និងទស្សនៈរបស់កុមារនៅពេលរៀបចំផែនការឬធ្វើសកម្មភាពការពារបរិស្ថាន។

១៧. ទប់ស្កាត់កុមារពីការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន និងបារីហើយផ្តល់នូវការព្យាបាលដល់កុមារដែលធ្លាប់បានប្រើប្រាស់។

១៨. ធានាថាកុមារទទួលបានការសិក្សាដោយឥតគិតថ្លៃបានយ៉ាងតិច៩ឆ្នាំជាមួយបរិយាកាសរៀនសូត្រសុវត្ថិភាព។ ធានាថាមានគ្រូបង្រៀនគ្រប់គ្រាន់នៅតាមសាលានៅជនបទ និងជួយកុមារដែលបោះបង់ឬឈប់រៀនបានចូលរៀនវិញគ្រប់គ្នា។

១៩. ឱ្យកុមារបានសម្រាក លេងកម្សាន្ត ដោយអនុវត្តសកម្មភាពខុសៗគ្នាដូចជា កីឡា សិល្បៈ។ ធានាសុវត្ថិភាពកន្លែងលេងកម្សាន្តរបស់កុមារ។

២០. ធានាថាកុមារមកពីក្រុមជនជាតិភាគតិច ទទួលបានការគោរព និងឱ្យតម្លៃដូចកុមារដទៃ និងទទួលបានសេវាសង្គមនានាផងដែរ។

២១. ការពារកុមារពីការរំលោភបំពាន ការធ្វើការងារសំណង់ ឡតដ្ឋ និងកន្លែងដែលអាចមានគ្រោះថ្នាក់ដទៃទៀត។ ជួយគាំទ្រដល់កុមារ ឬជួយយកកុមារចេញពីការរស់នៅតាមដងផ្លូវ ឬស្ថានភាពគ្រោះថ្នាក់។ បង្កើតនូវតុលាការ ឬវិធីធ្វើការបែបថ្មីដល់នគរបាល មេធាវី ចៅក្រម ឬតុលាការអាចជួយដល់កុមារទទួលបានយុត្តិធម៌។

# KEY RECOMMENDATIONS FROM THE UN COMMITTEE ON THE RIGHTS OF THE CHILD TO THE ROYAL GOVERNMENT OF CAMBODIA IN 2022




**1**. Make laws, plans, and programs (such as a child protection law) to protect and support children all over the country, and provide enough money to put these laws and programs into action so that all children can benefit.




**2**. Inform all parents, teachers, health and social workers, judges, lawyers, police, and others about children's rights and what can they do to make children's right real.




**3**. Make sure children of all backgrounds and identities can get public services, such as education and health, and check if this is really happening. Inform and teach everyone that all children, including girls, have equal rights.




**4**. Make campaigns on road safety, and do more to prevent traffic accidents.




**5**. Make sure that children's voices are heard in decisions that affect their lives, such as during an adoption process or in plans made that affect them in families, communities, and schools.




**6**. Make sure every child has their birth certificate and identity documents by improving the electronic registration system, and by prohibiting fees.







**7**. Make sure that all children can express themselves freely at home, in the communities, in schools, in public institutions, and on social media.




**8**. Support children to make their own organizations, clubs, and initiatives and to take part in public gatherings.







**9**. Develop rules to protect children's rights, their privacy, and their safety online on the internet, and support children, parents, teachers, and social workers to use the internet in a safe and respectful way.

**10**. Do not allow anyone to punish children using violence at home, in communities, and in schools. Support positive parenting. Provide one helpline that is free and open all the time, and help children to know how to use this line.






**11**. Make sure that children who are locked in a facility like prisons do not face violence and are able to secretly share their concerns about the way they are treated to someone outside.

**12**. Tell everyone about why child and forced marriage is harmful, and do more to stop people from doing this.







**13**. Allow children to stay in alternative care in their communities when their families are not able to care for them, such as with close relatives or with another family who can take good care of them.

**14**. Make sure all adoption is done following the law, and prevent children from being sold through adoption. Gather information about suitable families who can adopt in the country.







**15**. Tell everyone about the rights of children with disabilities, and make sure these children do not face any violence or unfair treatment.

**16**. Make programs to support the mental health of children, provide them education about their sexual and reproductive health and about the environment and climate change in schools, and consider children's needs, concerns, and views when making plans and taking action to protect the environment.







**17**. Prevent children from getting alcohol, drugs, and tobacco, and provide treatment programs for children who need it.

**18**. Make sure that children must get free education for at least 9 years and that the education environment is safe. Make sure there are enough teachers in remote schools and that children who left school are supported to return to school.










**19.** Allow children to rest and play by providing different activities and programs, such as sports and art. Make safe playground spaces.

**20**. Make sure children from smaller and traditional groups are all treated equally with other children and that they can get public services.






















**21**. Protect children from abuse, and do not allow them to work in construction, brickmaking, and other dangerous jobs. Provide support for children on the streets and children who are harmed or is taken away. Make new courts and methods for the police, lawyers, and judges so that can really help children to get justice.



# អនុសាសន៍ ឬសំណូមពរ
# សម្រាប់ផ្នែកច្បាប់ គោលនយោបាយ
# ការចាត់ចែងធនធានថវិកាសម្រាប់អនុវត្ត

Recommendation on Laws, Policies, and Resource Allocation



អង្គការសហប្រជាជាតិសំណូមពរឱ្យប្រទេសកម្ពុជាត្រូវ The UNCRC Committee recommends the Cambodian Government to:

## ការធ្វើឱ្យសិទ្ធិកុមារក្លាយជាការពិត
Making Rights Real

### ច្បាប់ Laws

- បង្កើនការអនុវត្តច្បាប់ដែលមានស្រាប់ស្របតាមសិទ្ធិកុមារ បង្កើតច្បាប់ស្ដីពីកិច្ចការពារកុមារឱ្យបានឆាប់ ដោយមានធនធានគ្រប់គ្រាន់។
- Ensure that the implementation of current laws follow the requirements of the CRC, and speed up the approval of a child protection law that is complete and has enough resources for implementation.
- បង្កើនចំណេះដឹងរបស់តុលាការ ព្រះរាជអាជ្ញា មេធាវី អំពីការអនុវត្តសិទ្ធិកុមារនៅក្នុងដំណើរការតុលាការ។
- Strengthen the knowledge of the courts, prosecutors, and lawyers on the applicability of the CRC in court proceedings.

### គោលនយោបាយ Policy

- បង្កើត និងអនុវត្តនូវគោលនយោបាយស្ដីពីកុមារ ដោយមានការចូលរួមពេញលេញពីកុមារ និងអង្គការសង្គមស៊ីវិល។
- Develop and implement a policy on children with full participation of children and civil society.

### ការសម្របសម្រួល Coordination

- ផ្ដល់អំណាច និងធនធានគ្រប់គ្រាន់ទៅដល់ដំណើរការ និងការអនុវត្តតួនាទីសម្របសម្រួលរបស់ក្រុមការងារទៅថ្នាក់ជាតិ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំសង្កាត់។
- Strengthen the authority and resources for the function and coordination roles of the institutions for children at national, provincial, district, and Commune levels.



## ការបែងចែកធនធានថវិកាសម្រាប់អនុវត្ត Resource Allocation

- បង្កើនការបែងចែកធនធានមនុស្ស និងថវិកាសម្រាប់ការងារកុមារ ជាពិសេសគិតគូរដល់កុមារី កុមារក្រីក្រ កុមារមានពិការភាព និងកុមារដទៃទៀត ដោយមានការចូលរួមពីកុមារ និងអង្គការសង្គមស៊ីវិល។
- Increase financial and human resources for all child related programs, particularly the rights of girls, poor children, children with disabilities, and others, and allow children and civil society to participate in monitoring and budgeting.
- ប្រឆាំងរាល់អំពើពុករលួយ និងបង្កើនសមត្ថភាពមន្ត្រីក្នុងការស្រាវជ្រាវ និងស្វែងរកជនល្មើសដែលប្រព្រឹត្តិអំពើពុករលួយ។
- Combat corruption and strengthen the ability of institutions to investigate cases and punish those responsible.

## ការធ្វើការងារជាមួយអង្គការសង្គមស៊ីវិល Cooperation with civil society

- ធានាថាអង្គការសង្គមស៊ីវិល អ្នកការពារសិទ្ធិមនុស្ស និងសិទ្ធិកុមារអាចធ្វើសកម្មភាពលើកកម្ពស់សិទ្ធិកុមារដោយសេរី។
- Ensure that civil society organizations and human rights defenders are able to promote children’s rights freely.
- មិនរារាំង បំភិតបំភ័យ ឬធ្វើបាបអង្គការសង្គមស៊ីវិល អ្នកការពារសិទ្ធិមនុស្ស និងសិទ្ធិកុមារក្នុងការអនុវត្តសិទ្ធិសេរីភាពបញ្ចេញមតិរបស់ពួកគេ។
- Do not harass, intimidate, retaliate, and do violence against civil society organizations and human rights defender, so that they can exercise their rights to freedom of expression.





## ការផ្សព្វផ្សាយ លើកកម្ពស់ការយល់ដឹង និងការបណ្តុះបណ្តាល Dissemination, awareness-raising, and training

- ពង្រឹងសកម្មភាពបង្កើតចំនេះដឹងពីសិទ្ធិកុមារ សម្រាប់កុមារ ឪពុកម្តាយ និងសាធារណជនទូទៅ។
- Strengthen the child rights awareness-raising programs for children, parents, and the public.

- លើកទឹកចិត្តឱ្យប្រព័ន្ធផ្សព្វផ្សាយធានាការគោរពសិទ្ធិកុមារ និងអនុវត្តសកម្មភាពផ្សព្វផ្សាយយ៉ាងទូលំទូលាយក្នុងទម្រង់ជាកុមារមេត្រី និងមានការចូលរួមពីកុមារ។
- Encourage the media to ensure sensitivity to children's rights, and implement all public outreach activities in a child-friendly manner and with involvement of children.
- បញ្ចូលនូវមេរៀនស្តីពីសិទ្ធិកុមារនៅក្នុងការបណ្តុះបណ្តាលមន្ត្រី នគរបាល មេធាវី តុលាការ គ្រប់កម្រិត និងអ្នកមានជំនាញដទៃទៀតដែលធ្វើការដើម្បី ឬជាមួយកុមារ។
- Include sections about the CRC in trainings for civil servants, police officers, and other professionals working with and for children.

# អនុសាសន៍ ឬសំណូមពរ
## សម្រាប់ផ្នែកគោលការណ៍ទាំងបួននៃអនុសញ្ញាស្តីពីសិទ្ធិកុមារ

## Recommendation on the Four General Principles of the CRC





## សិទ្ធិការពារពីការរើសអើងគ្រប់រូបភាព
No Discrimination



- ពិនិត្យតាមដាន ដោះស្រាយ និងលើកកម្ពស់ការយល់ដឹងជាប្រចាំនូវការអនុវត្តនូវទំនៀមទម្លាប់ដែលរារាំងសិទ្ធិកុមារដោយសារភេទរបស់ពួកគេ និងសកម្មភាពរើសអើងក្នុងការទទួលសេវារបស់រដ្ឋទាំងអស់ក្នុងចំណោមកុមារដែលមានប្រវត្តិ និងស្ថានភាពខុសៗគ្នា ជាពិសេសកុមារី។

- Regularly monitor, address, and raise awareness on all practices and action on gender stereotypes, discrimination of all forms, and gaps in access to public services by children from different backgrounds and identities, particularly girls.

## គិតគូរពីប្រយោជន៍របស់កុមារ
Best Interests Of The Child

- បង្កើត និងតាមដាននូវដំណើរការ និងការអនុវត្តសម្រាប់អ្នកមានតួនាទីនៅក្នុងសង្គមក្នុងការគិតគូរ ថ្លឹងថ្លែងជាចម្បងពីផលប្រយោជន៍ដ៏ច្រើនបំផុតសម្រាប់កុមារក្នុងការសម្រេចចិត្ត និងអនុវត្តសកម្មភាព។
- Develop, monitor, and evaluate procedures and performance of professionals to take the child’s best interests as a primary consideration.



## សិទ្ធិបញ្ចេញមតិ និងទទួលការគោរពលើមតិរបស់កុមារ
Respect For Children’s Views




- បញ្ចូលទស្សនៈរបស់កុមារនៅគ្រប់សេចក្តីសម្រេចចិត្តរបស់ស្ថាប័នរដ្ឋនានាទាំងដំណើរការយុត្តិធម៌ ឬច្បាប់ និងដំណើរការគ្រប់គ្រង។
- Make sure children's voices are heard in all decisions that may affect them, including any processes in court.
- ផ្តល់ធនធានសម្រាប់អនុវត្តសេចក្តីណែនាំជាតិស្តីពីការចូលរួមរបស់កុមារ។ ពង្រឹងសមត្ថភាព និងអំណាចរបស់កុមារជាពិសេសកុមារស្ថិតក្នុងស្ថានភាពលំបាក បានចូលរួមបញ្ចេញមតិពេញលេញនៅក្នុងគ្រួសារ សហគមន៍ និងសាលារៀន។
- Provide resources to implement the national guidelines on child participation. Empower children, in particular children living under harder situations, to participate meaningfully in the family, community, and schools.

## សិទ្ធិរស់រាន និងអភិវឌ្ឍន៍
Life, Survival, And Development

- អនុវត្តសកម្មភាពផ្សព្វផ្សាយទូលំទូលាយអំពីសុវត្ថិភាពចរាចរណ៍ និងការទប់ស្កាត់នូវគ្រោះថ្នាក់ចរាចរណ៍ចំពោះកុមារ ឪពុកម្តាយ និងមនុស្សគ្រប់រូប ដើម្បីពង្រឹងការងារទប់ស្កាត់កុមារពីគ្រោះថ្នាក់ទាំងនេះ។
- Carry out public campaigns on road safety and accident prevention for children, parents, and the public in order to strengthen methods to prevent children from getting into traffic accidents.





# អនុសាសន៍ ឬសំណូមពរ សម្រាប់ផ្នែកសិទ្ធិនិងសេរីភាពជាពលរដ្ឋរបស់កុមារ

## Recommendation on Civil Rights and Freedoms








- សំបុត្រកំណើត និងផ្តល់អត្តសញ្ញាណដល់កុមារគ្រប់រូបដោយមិនគិតពីប្រវត្តិ និងស្ថានភាពរបស់ពួកគេ រួមទាំងកុមារដែលកើតពីការពពោះជំនួស និងកុមារដែលមិនទាន់មានសញ្ជាតិ និងហាមឃាត់ការយកកម្រៃក្រៅផ្លូវការ។

- Register and provide identification for all children regardless of their backgrounds or situation, including children born through surrogacy and stateless children, and prohibit the practice of informal fees for the issuance.



- ផ្សព្វផ្សាយអំពីសារសំខាន់នៃការចុះសំបុត្រកំណើតទៅដល់កុមារ ឪពុកម្តាយ គ្រូបង្រៀន សហគមន៍ អាជ្ញាធរគ្រប់កម្រិត និងអ្នកធ្វើការជាមួយ និងដើម្បីកុមារ។

- Promote awareness on the importance of birth registration for children, parents, teachers, communities, authorities at different levels, and professionals working with and for children.

## សិទ្ធិសេរីភាពក្នុងការបញ្ចេញ និងចែករំលែកគំនិត និងទស្សនៈ
Sharing Thoughts Freely

## សិទ្ធិសេរីភាពក្នុងការគិត និងគោរពសាសនា
Freedom Of Thought And Religion




- ធានាសេរីភាពនៃការបញ្ចេញមតិរបស់កុមារគ្រប់រូប នៅគ្រប់ទីកន្លែង រួមទាំងប្រព័ន្ធផ្សព្វផ្សាយសង្គម។
- Guarantee the freedom of expression for all children at all settings including on social media.

## សិទ្ធិបង្កើតក្រុមឬសមាគម និងការជួបជុំ
Setting Up Or Joining Groups

- បញ្ចូលចំណុចណែនាំនៅក្នុងច្បាប់ក្នុងការរៀបចំបង្កើតសមាគមឬក្រុមដែលដឹកនាំដោយកុមារ ព្រមទាំងការពារនូវផលប្រយោជន៍របស់កុមារ។
- Provide legal rules that manage the establishment of child-led associations, ensuring that they safeguard the best interests of children.
- ផ្តល់ធនធាន និងការលើកទឹកចិត្តដល់កុមារគ្រប់រូបអាចបង្កើតនូវក្រុម ឬ សមាគម និងគំនិតផ្តួចផ្តើមឬសកម្មភាពនានារបស់ពួកគេ និងចូលរួមគ្រប់ការជួបជុំនានា។
- Provide resource and encouragement for all children to be able to forms their own associations and programs and to participate in public gathering.

## សិទ្ធិទទួលបានការពារការរក្សាការសម្ងាត់ និងភាពឯកជន
Protection Of Privacy

## សិទ្ធិទទួលបានព័ត៌មានសមស្រប
Access To Information



- បង្កើតច្បាប់ សេចក្តីណែនាំសម្រាប់ការពារសិទ្ធិរក្សាការសម្ងាត់ពីអត្តសញ្ញាណ និងឯកជនភាពរបស់កុមារ  និងសុវត្ថិភាពរបស់កុមារនៅក្នុងគ្រប់ប្រព័ន្ធឌីជីថល ឬអ៊ីនធើណេត។
- Develop regulations and safeguarding policies to protect the rights, privacy, and safety of children in the digital environment.
- ធានាថាសេចក្តីព្រាងច្បាប់ពាក់ព័ន្ធផ្តល់កិច្ចការពារសិទ្ធិឯកជនភាពរបស់កុមារ ហើយពួកគេត្រូវទទួលបាននូវព័ត៌មានសមស្រប និងមិនមានគ្រោះថ្នាក់។
- Ensure that the draft laws on access to information and cybercrime protect children’s rights to privacy and to access non-harmful content and materials.



- បង្កើនជំនាញសម្រាបកុមារ ឪពុកម្តាយ គ្រូបង្រៀន និងកម្លាំងសេវាសង្គមក្នុងការស្វែងរកព័ត៌មានតាមប្រព័ន្ធអនឡាញដោយសុវត្ថិភាព។
- Enhance the skills for children, parents, teachers, and social workers to find and evaluate information online.

# អនុសាសន៍ ឬសំណូមពរ
## លើផ្នែកអំពើហិង្សាលើកុមារ

## Recommendation on Violence Against Children



# សិទ្ធិការពារពីអំពើហិង្សា

## Protection From Violence



- លុបចោលនូវខ្លឹមសារមួយចំនួនដែលមានក្នុងច្បាប់ដែលអាចបង្កជាទណ្ឌកម្មលើកុមារ និងបញ្ចូលនៅក្នុងច្បាប់ឱ្យបានច្បាស់ពីការហាមប្រាមការដាក់ទណ្ឌកម្មលើកុមារគ្រប់ទម្រង់នៅគ្រប់ទីកន្លែងជាពិសេសនៅផ្ទះ សាលារៀន និងកន្លែងថែទាំកុមារ។
- Change laws that seem to allow the use of corporal punishment on children, and prohibit in the law corporal punishment in all settings, including at home and in childcare institutions.
- ផ្សព្វផ្សាយដល់ឪពុកម្តាយ អ្នកធ្វើការជាមួយឬដើម្បីកុមារ និងគ្រូបង្រៀនក្នុងការអនុវត្តការអប់រំកុមារ និងចិញ្ចឹមកូនតាមបែបវិជ្ជមាន និងគ្មានហិង្សា។
- Help parents, professionals working with and for children, and teachers to practice positive and non-violent parenting and teaching.
- បង្កើនការយល់ដឹងជាសាធារណៈអំពីផលប៉ះពាល់ដ៏គ្រោះថ្នាក់ នៃការរៀបការវ័យកុមារ និងការបង្ខំឱ្យកុមាររៀបការ និងការមានផ្ទៃពោះក្នុងវ័យជំទង់។
- Increase public awareness of the harmful effects of child and forced marriage on children and early pregnancy.
- ធ្វើសកម្មភាពលុបបំបាត់អំពើទាំងនេះជាពិសេសនៅតំបន់ជនជាតិដើមភាគតិច និងនៅជនបទ។
- Take all actions to get rid of these practices, particularly in indigenous, minority, and rural communities.

## សិទ្ធិការពារពីអំពើរំលោភបំពានផ្លូវភេទ
Protection From Sexual Abuse




- បញ្ចូលនិយមន័យអំពីគ្រប់ទម្រង់នៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមាររួមទាំងការលួងលោម ការរួមភេទរវាងសាច់ញាតិនៅក្នុងច្បាប់ពាក់ព័ន្ធនានា។
- Clearly define the acts of grooming, incest, and non-physical sexual abuse in related laws.
- ផ្តល់ធនធានសម្រាប់សកម្មភាពផ្សព្វផ្សាយ ការបង្កើនសមត្ថភាព និងការអនុវត្តការងាររបស់ក្រុម ឬសេវាការពារកុមារនៅតាមសហគមន៍។
- Provide enough resources to build the capacity and functions of the community-based child protection mechanisms and services.
- គ្រប់គ្រងការដោះស្រាយករណីនៃការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានលើកុមារ តាំងពីទទួលបានការរាយការណ៍ ការស្រាវជ្រាវ និងអន្តរាគមន៍ភ្លាមៗ។
- Make sure that acts of child exploitation and abuse are responded to right away and that the case is well managed.

## សិទ្ធិទទួលបានសេវាថែទាំ និងសេវាគាំទ្រដល់កុមាររងគ្រោះ
Recovery And Reintegration

- ពង្រឹង និងសម្របសម្រួលបណ្តាញទូរស័ព្ទផ្តល់ជំនួយដល់កុមារដែលមានរួមគ្នាតែបីខ្ទង់ ដោយមិនគិតថ្លៃហៅចូលគ្រប់ពេលវេលា។
- Strengthen and coordinate existing helplines for children into a single, three-digit, and free 24-hour helpline.
- បង្កើនសមត្ថភាពដល់បុគ្គលិកឆ្លើយតបបណ្តាញទូរស័ព្ទមានជំនាញក្នុងការដោះស្រាយ និងផ្តល់ជំនួយបែបកុមារមេត្រី។
- Enhance the capacity of helpline staff to handle complaints and provide child-friendly support.




1280
117
1280
117

# អនុសាសន៍ ឬសំណូមពរ

## សម្រាប់ផ្នែកសិទ្ធិទទួលបានការរស់នៅជាមួយគ្រួសារ និងការថែទាំជំនួស (ថែទាំពីអ្នកដទៃ)

## Recommendation on Family Environment and Alternative Care



## សិទ្ធិទទួលបានការណែនាំពីគ្រួសារដែលបានបណ្តុះបណ្តាល
Family Guidance As Children Develop

## សិទ្ធិជួបជុំ និងរស់នៅជាមួយគ្រួសារ
Keeping Families Together

## សិទ្ធិទទួលបានការត្រួតពិនិត្យឡើងវិញការទុកដាក់កុមារនៅពេលថែទាំ និងព្យាបាល
Review Of a Child’s Placement



- បញ្ឈប់ការទុកដាក់កុមារ នៅតាមមណ្ឌលថែទាំគ្រប់ប្រភេទ និងផ្តល់ជម្រើសសម្រាប់ពួកគេក្នុងការរស់នៅជាមួយគ្រួសារពួកគេផ្ទាល់ ឬគ្រួសារធម៌។
- Stop sending children to facilities, and strengthen options for them to stay with their own or other families.

- ពិនិត្យ និងចុះបញ្ជីបរិក្ខារសម្រាប់ថែទាំកុមារនានា និងបង្កើនចំនួនកម្លាំងសេវាសង្គមបន្ថែមទៀត ដើម្បីជួយដល់ការងារទាំងនេះ។
- Register and monitor alternative care facilities, and increase number of social service workers to support this work.
- ធានាកុមារដែលនៅក្នុងពន្ធនាគារជាមួយម្តាយរបស់ពួកគេទទួលបាននូវសេវាអប់រំ ការថែទាំសុខភាព ការអភិវឌ្ឍកុមារតូច និងកិច្ចការពារ។
- Provide education, health care, early childhood development, and protection for children in prisons with their mothers.





# សិទ្ធិទទួលបានកិច្ចការពារនៅក្នុងដំណើរការសុំ(ស្មូម)កុមារយកទៅចិញ្ចឹម

Children Who Are Adopted



- ស៊ើបអង្កេត និងកាត់ទោសបុគ្គលចូលរួមក្នុងសកម្មភាពសុំ(ស្មូម)កុមារយកមកចិញ្ចឹមដោយខុសច្បាប់ និងអំពើលក់ដូរកុមារដើម្បីធ្វើជាកូនចិញ្ចឹម។
- Investigate and punish people involved in illegal adoptions and the sale of children through adoption.
- ផ្តល់នូវការគាំពារដល់កុមារដែលរងគ្រោះ និងពង្រឹងសមត្ថភាពដល់មន្ត្រីទទួលខុសត្រូវនៅគ្រប់ដំណាក់កាលនីមួយៗនៃការសុំ(ស្មូម)កុមារយកមកចិញ្ចឹម។
- Provide support for children and train professionals involved in adoption procedures.
- លើកទឹកចិត្តការសុំ(ស្មូម)កុមារយកមកចិញ្ចឹមក្នុងស្រុកដោយមានដំណើរការច្បាស់លាស់ និងមានសុវត្ថិភាព។
- Promote domestic adoption with clear and safe procedures.





# អនុសាសន៍ ឬសំណូមពរ
# សម្រាប់ផ្នែកកុមារមានពិការភាព

## Recommendation on Children with Disabilities





- បញ្ចូលនូវការលុបបំបាត់ការរើសអើង និងអំពើហិង្សាលើកុមារមានពិការភាពនៅរាល់ការបង្កើតច្បាប់ ការត្រួតពិនិត្យការអនុវត្តច្បាប់ និងគោលនយោបាយពាក់ព័ន្ធនានា។

- Make and implement laws and rules that ensure children with disabilities do not face discrimination and violence.

- ពង្រឹងការយល់ដឹងជាសាធារណៈពីសិទ្ធិកុមារមានពិការភាព និងការគាំទ្រដល់កុមារមានពិការភាព ជាពិសេសកុមារមានពិការភាពផ្លូវចិត្ត និងកុមារចំណាកស្រុក។

- Improve public awareness on rights of children with disabilities, and provide support for them, particularly children with psychosocial disabilities and migrant children.



# អនុសាសន៍ ឬសំណូមពរ

## សម្រាប់ផ្នែកសុខភាព និងសុខុមាលភាពសម្រាប់កុមារ

Recommendation on Health and Welfare



# សិទ្ធិទទួលបាននូវសេវាសុខភាព អាហារ និងទឹកស្អាត

Health, Water, Food, Environment




- បង្កើនគុណភាពនៃសេវាសុខភាពទៅដល់កុមារគ្រប់រូបដើម្បីកាត់បន្ថយអត្រាមរណៈរបស់ទារក និងកុមារអាយុក្រោម៥ឆ្នាំ និងផ្តល់សេវា និងសកម្មភាពថែទាំសុខភាពផ្លូវចិត្តសម្រាប់កុមារនៅតាមសហគមន៍ សាលារៀន ផ្ទះ និងកន្លែងថែទាំកុមារ។។
- Make health services better to a void death of children under 5 years old, and provide mental health programs for children in community, schools, homes, and alternative care institutions.

- ផ្តល់នូវសម្ភារទឹកស្អាត និងអនាម័យដល់គ្រប់មណ្ឌលសុខភាព ជាពិសេសនៅជនបទ។
- Provide water and cleaning facilities in all health centers, such as in remote areas.
- ដោះស្រាយមូលហេតុ និងផលប៉ះពាល់នៃបញ្ហាខ្វះអាហារមានជីវជាតិ ទម្ងន់មិនគ្រប់ ក្រិន និងស្លេកស្លាំងរបស់កុមារ ។
- Look into why children do not get enough food and nutrients, and make solutions.
- ផ្តល់នូវកម្មវិធីសិក្សាសុខភាពផ្លូវភេទនៅតាមសាលារៀន និងព័ត៌មាននៅតាមសហគមន៍។
- Provide sexual education in schools and child-friendly sexual and reproductive health information and services.
- ធានាថាកុមារីទទួលបាននូវសេវាធ្វើផែនការគ្រួសារ សេវាពន្យាកំណើត សេវារំលូតកូនប្រកបដោយសុវត្ថិភាព។
- Make sure girls can get family planning services, tools to control pregnancy, and safe abortion care services.



## សិទ្ធិរស់រាន និងអភិវឌ្ឍន៍
Life, Survival, And Development

## សិទ្ធិទទួលកិច្ចការពារពីគ្រឿងញៀន និងគ្រឿងស្រវឹង
Protection From Harmful Drugs



- បញ្ចូលមេរៀនបម្រែបម្រួលអាកាសធាតុក្នុងការអប់រំបរិស្ថាននៃកម្មវិធីសិក្សានៅក្នុងសាលារៀន។
- Add a lesson on climate change in environmental education in the school curriculum.
- ធានាថាទស្សនៈរបស់កុមារត្រូវបានពិចារណានៅពេលបង្កើតនូវគោលនយោបាយសកម្មភាព និងការសម្រេចចិត្តដទៃទៀតអំពីការគ្រប់គ្រងបញ្ហាបម្រែបម្រួលអាកាសធាតុ និងគ្រោះធម្មជាតិ។
- Ensure that children’s ideas are taken into account in making policies, actions, and other decisions on disaster risk management and climate change.
- ដាក់ឱ្យអនុវត្តនូវច្បាប់គ្រប់គ្រងគ្រឿងស្រវឹងដែលកំណត់ច្បាស់លាស់ពីអាយុអប្បបរមាក្នុងការប្រើប្រាស់។
- Make a law that explains at what age people can start drinking alcohol.
- ផ្តល់ឱ្យកុមារនូវព័ត៌មានត្រឹមត្រូវពីការបង្ការការសេពគ្រឿងញៀន គ្រឿងស្រវឹង និងបង្កើតសេវាជួយព្យាបាល និងថែទាំកុមារដែលញៀនបែបកុមារមេត្រី។
- Provide information about the use of substances like drugs, tobacco, and alcohol, and provide child-friendly treatment and services that can be reached by children.



# អនុសាសន៍ ឬសំណូមពរ សម្រាប់ផ្នែកអប់រំ សកម្មភាព កម្សាន្ត និងវប្បធម៌សម្រាប់កុមារ

## Recommendation on Education, Leisure, and Cultural Activities



# សិទ្ធិទទួលបានការអប់រំ

Access To Education

# សិទ្ធិទទួលបាននូវគុណភាពនៃការសិក្សាអប់រំ

Aims Of Education



- ធ្វើឱ្យប្រសើរនូវគុណភាពនៃការអប់រំគ្រប់កម្រិត ទាំងរដ្ឋ និងឯកជនដោយធានានូវការអប់រំជាកាតព្វកិច្ច និងមិនគិតថ្លៃយ៉ាងហោចណាស់ថ្នាក់ទី៩ បរិយាកាសសិក្សាមានសុវត្ថិភាព និងអនាម័យ ធនធាន សម្ភារ និងគ្រូគ្រប់គ្រាន់។

- Improve the quality of public and private education at all levels by ensurring that education is required and free for all children for at least 9 years, with a safe and clean learning environment and enough resources, facilities, and teachers.

- ការពារ និងគាំទ្រកុមារមានពិការភាព កុមារមាននិន្នាការភេទ ឬអត្តសញ្ញាណភេទខុសៗគ្នា និងកុមារជនជាតិដើមភាគតិចបានចូលរៀនប្រកបដោយគុណភាព និងមានគ្រូជំនាញសម្រាប់ពួកគេ។

- Protect and support children with disabilities, LGBTI children, and children in minority and indigenous community to get quality education with skillful teachers.





## សិទ្ធិរបស់កុមារជាជនជាតិភាគតិច
Minority Culture, Language, And Religion

## សិទ្ធិសម្រាក លេងកម្សាន្ត និងចូលរួមសកម្មភាពវប្បធម៌ និងសិល្បៈ
Rest, Play, Culture, Arts



- ធានាសិទ្ធិរបស់កុមារក្នុងការសម្រាក កម្សាន្ត ចូលរួមសកម្មភាពកីឡា ច្នៃប្រឌិត វប្បធម៌ សិល្បៈនានាដោយសេរី មិនមានការរារាំង និងកន្លែងកម្សាន្តសម្រាប់កុមារត្រូវតែមានសុវត្ថិភាព។



- Protect the right of children to rest and leisure, to engage in age appropriate recreational activities, sports, cultural life, and the arts, and to have safe playground spaces.





# អនុសាសន៍ ឬសំណូមពរ

## សម្រាប់ផ្នែកកិច្ចការពារពិសេសសម្រាប់កុមារ

## Recommendation on Special Protection



30

# សិទ្ធិរបស់កុមារជាជនជាតិភាគតិច

## Minority Culture, Language, And Religion



- លុបបំបាត់រាល់ការរើសអើងចំពោះកុមារជនជាតិភាគតិច ឬកុមារជនជាតិដើមភាគតិច និងផ្តល់ពួកគេនូវសិទ្ធិទទួលបានសេវាចុះសំបុត្រកំណើត និងឯកសារសម្គាល់ខ្លួន ការថែទាំសុខភាព ការអប់រំ លំនៅដ្ឋាន និងសេវាដទៃទៀត។

- Fight discrimination against children in minority or indigenous groups, and make sure they can get birth registration, identity documents, health care, education, housing, and other services.

## សិទ្ធិការពារពីការងារដែលមានគ្រោះថ្នាក់

Protection From Harmful Work

## សិទ្ធិការពារពីអំពើកេងប្រវ័ញ្ចគ្រប់រូបភាព

Protection From Exploition



- ពិចារណាទទួលយកច្បាប់អន្តរជាតិពាក់ព័ន្ធ នឹងពលករតាមផ្ទះមកអនុវត្តនៅក្នុងប្រទេស និងពង្រឹងការអនុវត្តច្បាប់ និងគោលនយោបាយស្តីពីពលកម្មកុមារ។
- Think about joining an international agreement for people who work at home, and implement laws on child labor.
- ហាមឃាត់យ៉ាងម៉ឺងម៉ាត់ចំពោះការទទួលយកកុមារឱ្យធ្វើការ ដែលមានគ្រោះថ្នាក់ និងបង្កើតបញ្ជីការងារគ្រោះថ្នាក់ដែលត្រូវបានហាមឃាត់សម្រាប់កុមារ។
- Change the law to ban children from working in harmful and dangerous types of work.
- ផ្តល់ជំនាញ និងចំណេះដឹងបន្ថែមសម្រាប់នគរបាល អាជ្ញាធរ មេធាវី តុលាការ និងផ្តល់នូវធនធានមនុស្ស និងថវិការក្នុងការអនុវត្តច្បាប់ និងផែនការសកម្មភាពប្រឆាំងនឹងពលកម្មកុមារ។
- Increase skills and knowledge for police officers, authorities, lawyers, and judges, and provide support to implement laws and action plans about child labor.



## សិទ្ធិការពារពីអំពើទារុណកម្ម បន្ទាបបន្ថោក ឬចាប់ឃុំឃាំងដោយមិនត្រឹមត្រូវ

Children In Detention




- លុបបំបាត់រាល់ទម្រង់នៃការចាប់ឃុំខ្លួនតាមអំពើចិត្ត និងការធ្វើបាបចំពោះកុមាររស់នៅតាមដងផ្លូវ ព្រមទាំងបង្កើតនូវកម្មវិធីផ្តល់នូវការជួបជុំគ្រួសារ និងការគាំទ្រផ្នែកសង្គម និងផ្លូវចិត្តដល់ពួកគេ និងគ្រួសាររបស់ពួកគេ។
- Make sure children are not detained without good reason, and make programs for children living on the streets to meet their family and receive different types of support.

## សិទ្ធិទទួលបានយុត្តិធម៌ចំពោះមុខច្បាប់

Children Who Break The Law

- ពង្រឹងការអនុវត្តច្បាប់ស្តីពីយុត្តិធម៌សម្រាប់កុមារ ដូចជាចាត់ចែងធនធានឱ្យបានគ្រប់គ្រាន់សម្រាប់អនុវត្ត ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ ផ្តល់សេវានានា និងសម្របសម្រួលការត្រឡប់ទៅក្នុងសហគមន៍វិញសម្រាប់កុមារ។
- Implement the law by providing enough resources, building the skills of people working in the justice system, taking children out of the justice system, and providing services (like counseling and support for returning to the community).
- ដកសេរីភាពរបស់កុមារគឺជាជម្រើសចុងក្រោយប៉ុណ្ណោះ ហើយធ្វើបានតែក្នុងរយៈពេលខ្លីតាមដែលអាចធ្វើបាន។
- Detain children only if all other options have been considered, and detain only for the shortest possible period of time.
- បង្កើតតុលាការបែបកុមារមេត្រីដែលមានដំណើរការត្រឹមត្រូវ និងសម្ភារគ្រប់គ្រាន់ ហើយផ្តល់នូវសេវាជំនួយផ្នែកច្បាប់ដោយមិនគិតថ្លៃ និងពីអ្នកជំនាញត្រឹមត្រូវសម្រាប់កុមារគ្រប់រូប។
- Make courts and procedures that concentrate only on children, and provide good and free legal support for all children being blamed for breaking the law.



# សិទ្ធិការពារពីអំពើលក់ និងជួញដូរកុមារ

## Prevention Of Sale And Trafficking



- ពិនិត្យនូវការអនុវត្តផែនការសកម្មភាពក្នុងការលុបបំបាត់អំពើជួញដូរមនុស្ស និងជំរុញការអនុវត្តឱ្យបានត្រឹមត្រូវ។
- Check if the action plan on trafficking is working well, and implement the plan properly.
- ផ្តល់នូវដំណើរការកំណត់អត្តសញ្ញាណ និងបញ្ជូនកុមាររងគ្រោះបែបកុមារមេត្រី ស៊ើបអង្កេត និងដាក់ទោសជនល្មើសគ្រប់ករណីជួញដូរកុមារទាំងអស់តាមនីតិវិធីកុមារមេត្រី។
- Provide procedure to identify and refer child survivors from trafficking to child-friendly services, and investigate and punish all cases of child trafficking using child-friendly proceedings.
- បង្កើនការផ្សព្វផ្សាយអំពីច្បាប់ និងកិច្ចការពារកុមារពីអំពើជួញដូរនៅតាមសហគមន៍។
- Increase awareness raising on laws, and protect children from trafficking in the communities.





ការបញ្ជាក់៖ ខ្លឹមសារជាភាសាអង់គ្លេសគឺជាការសម្រួលសង្ខេបពីខ្លឹមសារដើមនៃសេចក្ដីអង្កេតចុងក្រោយរបស់អង្គការសហប្រជាជាតិ ឆ្នាំ២០២២។ ខ្លឹមសារជាភាសាខ្មែរត្រូវបានសង្ខេបដោយមានកិច្ចសហការជាមួយកុមារ ហើយបានសម្រួលឱ្យត្រូវនឹងបរិបទ និងសមស្របសម្រាប់កុមារដោយមិនបកប្រែពីភាសាអង់គ្លេសគ្រប់ពាក្យ និងឃ្លានោះទេ តែអត្ថន័យគឺតែមួយ។

Disclaimer: This booklet is a child-friendly version of the recommendations provided by the UN Committee on the Rights of the Child to the Cambodian government in the Concluding Observations (COBs) issued in June 2022. The English and Khmer content was summarized and reworded from the COBs, in partnership with children in Cambodia. The Khmer content was further contextualized for Cambodia and for children based on consultations with them, but retains the overall meaning as in English.

រក្សាសិទ្ធិដោយអង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា ឆ្នាំ២០២៣
សញ្ញារូបភាពដោយអង្គការយូនីសេហ្វ ឆ្នាំ២០១៩
រូបភាពដោយអង្គការមូលនិធិសិទ្ធិកុមារ និងអង្គការភ្លែនអន្តរជាតិ

All rights reserved © Child Rights Coalition Cambodia, 2023

Icon Designs © UNICEF, 2019

Illustrations © Child Rights Foundation Organization and Plan International

ផលិតដោយ / Produced by

គាំទ្រដោយ / Supported by


**អាសយដ្ឋានទំនាក់ទំនង៖**

ផ្ទះលេខ៨អា ផ្លូវលេខ១៣៨ សង្កាត់វាលវង់
ខណ្ឌ៧មករា រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

Address of Child Rights Coalition Cambodia: #8A,
Street 138,Veal Vong,7 Makara, Phnom Penh, Cambodia

ទូរសព្ទទំនាក់ទំនង Telephone: +855 23 882 412
អ៊ីមែល E-mail : info@crc-cambodia.org
គេហទំព័រ Website address: www.crc-cambodia.org



ផលិតនៅខែកុម្ភៈឆ្នាំ២០២៣
Developed in February 2023